**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ០៧១.........សហវ.....

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមការងារចំពោះកិច្ច ដើម្បីសិក្សាអំពីឧស្សាហកម្មសារពើពន្ធអេឡិចត្រូនិក

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ/បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើត ក្រុមការងារសារពើពន្ធអេឡិចត្រូនិក ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | បណ្ឌិត **គង់ ម៉ារី** | ជំនួយការឯកឧត្ដមបណ្ឌិតសភាចារ្យទេសរដ្ឋមន្ត្រី | ប្រធាន |
| ២. | បណ្ឌិត **ចន ណារិទ្ធ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគោលនយោបាយ | អនុប្រធាន |
| ៣. | លោក **មន្ត ប្រាជ្ញា** | ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គលេខាធិការដ្ឋាន | អនុប្រធាន |
| ៤. | លោក **លឹម ជីលុច** | ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

| | | | |
|---|---|---|---|
| ៥. | លោក **សុខ សុវិទ្យា** | ប្រធាននាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ៦. | លោក **ជា វណ្ណារ័ត្ន** | ប្រធាននាយកដ្ឋានចំណូលថវិកា នៃអគ្គនាយកដ្ឋានរតនាគារជាតិ | សមាជិក |
| ៧. | លោក **ម៉ាន ប៊ុនណារិត** | ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ | សមាជិក |
| ៨. | បណ្ឌិត **ខាន់ វណ្ណៈ** | អនុប្រធាននាយកដ្ឋានថវិកានីយកម្ម នៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ៩. | លោក **ជ័យ រិទ្ធី** | អនុប្រធាននាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១០. | លោក **សៀង ស៊ីថា** | អនុប្រធាននាយកដ្ឋានសវនកម្មសហគ្រាស នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១១. | លោក **សួន សុភាព** | អនុប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក និងផែនការ នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិក |
| ១២. | លោក **ទីវ និដ្ឋានុ** | អនុប្រធាននាយកដ្ឋានទីផ្សារ និងស្ថាប័នហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | សមាជិក |
| ១៣. | លោក **ជា សំណាង** | ប្រធានការិយាល័យកិច្ចការអន្តរជាតិ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ១៤. | បណ្ឌិត **ជួន ច័ន្ទសោភា** | ប្រធានការិយាល័យស្ថិតិ និងប្រព័ន្ធព័ត៌មានវិទ្យា នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ១៥. | លោក **ជា សំអុន** | ប្រធានការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ១៦. | លោក **ហេង សុធី** | អនុប្រធានការិយាល័យនៃនាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៧. | លោក **ធាន ធីរិទ្ធ** | អនុប្រធានការិយាល័យគ្រប់គ្រងទិន្នន័យ នៃអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ១៨. | លោក **ទីវ ប៊ុលីន** | មន្ត្រីគយការិយាល័យគ្រប់គ្រងវិនិយោគមិនមែនកាត់ដេរ នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា | សមាជិក |
| ១៩. | លោក **ហេង សុជាតិ** | មន្ត្រីនាយកដ្ឋានគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធ នៃអគ្គនាយកដ្ឋានគោលនយោបាយ | សមាជិក |
| ២០. | លោក **ផ ម៉េងឡាយ** | មន្ត្រីនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃអគ្គលេខាធិការដ្ឋាន | សមាជិក។ |

**ប្រការ ២.**

ក្រុមការងារសារពើពន្ធអេឡិចត្រូនិក មានភារកិច្ចដូចខាងក្រោម÷

- សិក្សាស្រាវជ្រាវ និងរៀបចំឯកសារទស្សនាទានស្តីពីការគ្រប់គ្រង និងការប្រមូលចំណូលសារពើពន្ធគ្រប់ប្រភេទពីប្រតិបត្តិការធុរកិច្ច និងអាជីវកម្មបែបអេឡិចត្រូនិក បែបឌីជីថល ឬដែលប្រើប្រព័ន្ធអ៊ីនធើណែត ស្របតាមឧត្តមានុវត្តន៍ជាអន្តរជាតិ,

- សិក្សាស្រាវជ្រាវ និងរៀបចំឯកសារទស្សនាទានស្ដីពីការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រង និងប្រមូលចំណូលសារ-ពើពន្ធគ្រប់ប្រភេទពីប្រតិបត្តិការធុរកិច្ច និងអាជីវកម្មបែបអេឡិចត្រូនិក បែបឌីជីថល ឬដែលប្រើប្រព័ន្ធអ៊ិនធើ-ណែត ស្របតាមឧត្តមានុវត្តជាអន្តរជាតិ,
- វិភាគទិន្នន័យសារពើពន្ធទទួលបានពីអង្គភាពពាក់ព័ន្ធ សម្រាប់គោលដៅសិក្សានិងស្រាវជ្រាវ ជាពិសេសពាក់ព័ន្ធនឹងការធ្វើធុរកិច្ច និងអាជីវកម្មបែបអេឡិចត្រូនិក បែបឌីជីថល ឬដែលប្រើប្រព័ន្ធអ៊ិនធើណែត,
- ផ្ដល់យោបល់ស្ដីពីការកែសម្រួលគោលនយោបាយ និងវិធានការចាំបាច់នានាពាក់ព័ន្ធនឹងការគ្រប់គ្រង និងការប្រមូលចំណូលសារពើពន្ធគ្រប់ប្រភេទពីប្រតិបត្តិការធុរកិច្ច និងអាជីវកម្មបែបអេឡិចត្រូនិក បែបឌីជីថល ឬដែលប្រើប្រព័ន្ធអ៊ិនធើណែត,
- រៀបចំសំណើគោលនយោបាយ និងវិធានការរដ្ឋបាលពាក់ព័ន្ធនឹងការគ្រប់គ្រង និងការប្រមូលចំណូលជាតិពីប្រតិបត្តិការធុរកិច្ច និងអាជីវកម្មបែបអេឡិចត្រូនិក បែបឌីជីថល ឬដែលប្រើប្រព័ន្ធអ៊ិនធើណែត។

**ប្រការ ៣.-**

ក្រុមការងារត្រូវរាយការណ៍អំពីលទ្ធផលការងារ និងអនុសាសន៍របស់ខ្លួនជូនទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងរយៈពេល ៦ ខែ បន្ទាប់ពីសេចក្ដីសម្រេចនេះត្រូវបានចុះហត្ថលេខា ។

**ប្រការ ៤.-**

សមាសភាពនៃក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានត្រូវកោះអញ្ជើញ និងដឹកនាំកិច្ចប្រជុំជំនួស តាមការប្រគល់សិទ្ធិពីប្រធាន។

**ប្រការ ៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃសុក្រ ៥ កើត ខែបុស្ស ឆ្នាំរកា ព.ស. ២៥៦១

ត្រូវនឹងថ្ងៃទី ២២ ខែធ្នូ គ.ស. ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ